# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២ . សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារពិសេសអន្តរក្រសួង_ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ/បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្តីសំរេច លេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០១ និង ៤១ សសរ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ
- យោងស្មារតីនៃកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីកម្មវិធីការងារសំរាប់អនុវត្តកាតព្វកិច្ចរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៤

## សំ រេ ច

**ប្រការ ១ :** បង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័នដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣- ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៤- ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៥- ឯកឧត្តម **ញ៉ុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ សមាជិក

៧- ឯកឧត្តម **ពូ គីមឈុន** ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សមាជិក

៦- លោក **ហុខ ថា** ប្រធាននាយកដ្ឋានពន្ធដារ សមាជិក

៧- លោក **ស៊ុត នារា** ប្រធាននាយកដ្ឋានកាំកុងត្រូល សមាជិក

៨- លោក **ស៊ាន ម៉ិនឈាង** អនុប្រធានទី១នៃនាយកដ្ឋាននគរបាលសេដ្ឋកិច្ច សមាជិក

៩- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខាធិការ

**ប្រការ ២ :** ក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័នដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម មានភារកិច្ចជាបន្ទាន់ដូចតទៅ :

ទី១- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយចំណាយជាប្រាក់ សំរាប់អន្តរការិយកម្ម ក្នុងការនាំចេញ ការនាំចូល ។

ទី២- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយបែបបទ ឬលុបចោលបែបបទដែលជាន់គ្នា ក្នុងការគ្រប់គ្រងកិច្ចដំណើរការពាណិជ្ជកម្ម ។

ទី៣- លើក ហើយដាក់ឱ្យអនុវត្តនូវវិធានការកាត់បន្ថយពេលវេលាក្នុងការនាំចេញ ការនាំចូលទំនិញ ។

ទី៤- លើក ហើយដាក់ឱ្យអនុវត្តនូវរាល់វិធានការបង្កើនចំណូលចូលថវិការដ្ឋ ។

រាល់វិធានការនៃភារកិច្ចទី១ ទី២ និងទី៣ ខាងលើនេះ គ្រាន់តែជាផ្នែកមួយនៃកាតព្វកិច្ចរបស់កម្ពុជាក្នុងឋានៈជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកដែលក្រសួងពាណិជ្ជកម្មបាននិងកំពុងដឹកនាំបំពេញតាមការសំរេចរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ។

**ប្រការ ៣ :** ភារកិច្ចខាងលើនេះ ត្រូវសំរេចឱ្យបានជាលទ្ធផលដែលគេអាចគណនាជាតួលេខបាន ។

**ប្រការ ៤ :** ក្រុមការងារពិសេសត្រូវរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីបណ្តាវិធានការនានាដែលបានដាក់ចេញ ។ ក្នុងករណីដែលមានវិធានការលើសសមត្ថកិច្ចរបស់ខ្លួន ក្រុមការងារពិសេសត្រូវរាយការណ៍ សុំការណែនាំ និងការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៥ :** ប្រធានក្រុមការងារពិសេសអាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ ៦ :** ក្នុងករណីចាំបាច់ក្រុមការងារនេះ អាចសហការជាមួយអ្នកផ្តល់ជំនួយ និង/ឬ ភាគីពាក់ព័ន្ធមកពីវិស័យឯកជន ដើម្បីសំរេចបានប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចខាងលើ ។

**ប្រការ ៧ :** ក្រុមការងារពិសេសនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៨ :** អាណត្តិរបស់ក្រុមការងារនឹងបញ្ចប់នៅពេលដែលយន្តការរបស់រាជរដ្ឋាភិបាលអំពីការដឹកនាំអនុវត្តយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យឯកជន និងកម្មវិធីកែលំអបរិយាកាសវិនិយោគនៅកម្ពុជាត្រូវបានកំណត់ឡើង ។ ក្នុងន័យនេះ ក្រុមការងារត្រូវលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលស្តីពីយន្តការនេះ ក្នុងរយៈពេលយ៉ាងខ្លីបំផុត ។

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ